- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន ស.រកត-១០-៩៤ -៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

**សំរេច**

**មាត្រា ១ :** យោងតាមស្មារតីមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា កោះគឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ២ :** ក្នុងន័យនេះ ដីដែលដុះចាស់ ឬថ្មីជាកោះ នៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួរ ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសថាជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតអោយឯកជន ឬ សមូហភាពណាប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រី ទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្ត អោយសំរេច តាមអនុក្រឹត្យនេះរៀង ៗ ខ្លួន ចាប់តាំងពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខាតរ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៥៤ អនក្រ.បក**

**ស្ដីពីកិច្ចសន្យា និង កិច្ចព្រមព្រៀងពាណិជ្ជកម្ម ឬ ការខ្ចីបុលដែលទាក់ទង និង ចំណាយថវិការដ្ឋ**

**រាជរដ្ឋាភិបាល**

www.pheakdeylaw.com

- បានឃើញច្បាប់សារពត៌មានដែលរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញថ្ងៃទី០៦ ខែ មេសា ឆ្នាំ ១៩៩២ និតិកាលទី១ ជំពូក២ មាត្រាទី ១០ ។
- បានឃើញលិខិត អនុញ្ញាតច្បាប់បើកកាសែត « ចលនាថ្មី » លេខ ០២៨/៩៥ ពម. ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥ ។

**សំរេច**

**ប្រការ ១ :** ដោយឃើញការមិនចេញផ្សាយ គ្មានបញ្ជាក់ពីមូលហេតុច្បាស់លាស់បន្ទាប់ពីកាសែត «ចលនាថ្មី» ច្បាប់ចេញផ្សាយលេខ ៣ ចុះថ្ងៃទី ២០-០១-១៩៩៥ រហូតមកដល់បច្ចុប្បន្នក្រសួងពត៌មាន សូមប្រកាសបិទសារពត៌នេះជាស្ថាពរ ។

**ប្រការ ២ :** នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោក **រាជដ្ឋ ឧីត្តុយារ៉ាករ** ចាងហ្វាងកាសែត «ចលនាថ្មី» ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរបស់ខ្លួន ។

**ប្រការ ៣ :** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ខៀវ កាញារីទ្ធ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៥

**ប្រកាសលេខ : ១៣១/៩៥ ពម.ប្រក**

**ស្តីពីការបិទសារពត៌មាន «សម្រែកនារីស្ត្រីខ្មែរ»**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់សារពត៌មានដែលរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញថ្ងៃទី០៦ ខែ មេសា ឆ្នាំ ១៩៩២ និតិកាលទី១ ជំពូក២ មាត្រាទី ១០ ។

www.pheakdeylaw.com